**អង្គភាពសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
**Civil Party Lead Co-Lawyers' Section**
**Section des co-avocats principaux des parties civiles**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 06-May-2016, 15:10
CMS/CFO: Sann Rada

# លិខិត

**ផ្ញើជូន៖** ឯកឧត្តមប្រធាន **គង់ ស្រ៊ីម** និង លោក លោកស្រីចៅក្រម នៃអង្គជំនុំជម្រះតុលាការកំពូល នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**យោង៖** វិធាន ២១ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ចម្លងជូន៖** ភាគីពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
ការិយាល័យរដ្ឋបាល

**កម្មវត្ថុ៖ ការចេញសាលដីកាបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១**

វិធានផ្ទៃក្នុងទទួលស្គាល់ សិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានការជូនព័ត៌មាន[1] និងទទួលបានការសម្រេចសេចក្តីលើការចោទប្រកាន់ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ក្នុងរយៈពេលមួយសមស្រប[2] ថាជាគោលការណ៍ជាសារវន្តរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ដោយឈរលើមូលដ្ឋាននេះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមដាក់លិខិតនេះ ដើម្បីសុំការបញ្ជាក់ពីកាលបរិច្ឆេទនៃការចេញសាលដីកាបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ដោយមានក្តីបារម្ភ បន្ទាប់ពីបានឃើញព័ត៌មាន នៅក្នុងផែនការបំពេញកិច្ចការរបស់ អ.វ.ត.ក ដែលត្រូវបានធ្វើវិសោធនកម្មលើកទី៨ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ ("*ផែនការបំពេញកិច្ចការ*") និងដែលបានចេញផ្សាយនៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៦។ នៅពេលដែលសវនាការលើបណ្តឹងសាទុក្ខត្រូវបានបញ្ចប់នៅថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០១៦ ផែនការបំពេញកិច្ចការនេះបានបង្ហាញថាសាលដីកាលើបណ្តឹងសាទុក្ខត្រូវបានរំពឹងទុកថា នឹងចេញនៅត្រីមាសទីពីរក្នុងឆ្នាំ២០១៦។ វិសោធនកម្មលើកទី៨ នៃផែនការបំពេញកិច្ចការរបស់ អ.វ.ត.ក ដែលបានចេញផ្សាយទើបតែប៉ុន្មានថ្ងៃនេះ បានកែប្រែ ផែនការនេះដោយរំពឹងថានឹងចេញសាលដីការនៃសំណុំរឿង ០០២/០១ នៅពាក់កណ្តាលត្រីមាសទីបីក្នុង ឆ្នាំ២០១៦ ទៅវិញ។ សាលក្រមរបស់សាលាដំបូងក្នុងសំណុំរឿង ០០២/០១ បានចេញនៅខែកក្កដា ឆ្នាំ២០១៤។ រហូតដល់ពេលនេះ គឺប្រហែលជា

---

[1] វិធាន២១(១)(គ) នៃវិធានផ្ទៃក្នុង

[2] វិធាន២១(៤) នៃវិធានផ្ទៃក្នុង

ជិតពីរឆ្នាំបានកន្លងផុតទៅហើយ ហើយការពន្យាពេលផ្សេងទៀតនឹងប៉ះពាល់ដល់វ័យចាស់ជរារបស់ជនជាប់ចោទ ដោយពេលនេះលោក នួន ជា មានអាយុ ៨៩ និង លោក ខៀវ សំផន មានអាយុ៨៤ឆ្នាំ ទៅហើយ។

ចំណែកឯ ដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងនៅក្នុងដំណើរការនីតិវិធីនេះតាំងពីឆ្នាំ ២០០៧ មកម្ល៉េះ។ មានដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន មានវ័យចាស់ជរា ហើយមានដើមបណ្តឹងរដ្ឋប្បវេណីប្រមាណ ៥០នាក់ បានទទួលមរណភាព ក្នុងកំឡុងពេលនីតិវិធីក្នុងសំណុំរឿង ០០២/០១ ទាំងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងតុលាការកំពូល។ អាស្រ័យហេតុនេះ សហមេធាវីនាំមុខ សូមទទូចសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលចេញសាលដីកាស្ថាពរក្នុងសំណុំរឿង០០២/០១ ដោយគ្មានការពន្យាពេលទៀតឡើយ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៦

**សហមេធាវីជាតិនាំមុខ**
**តំណាងដើមបណ្តឹងរដ្ឋប្បវេណី**



**ពេជ អទ្ត**

**សហមេធាវីអន្តរជាតិនាំមុខ**
**តំណាងដើមបណ្តឹងរដ្ឋប្បវេណី**



**ម៉ារី ហ្គីរ៉ូដ**